00744292

E118/3

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១


**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 04 / 10 / 2011
ម៉ោង (Time/Heure): 10:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak


**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង

ប្រភេទនៃចំណាត់ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**យោបល់ទាក់ទិននឹងសំណើរបស់លោក អៀង សារី**

**សុំពិនិត្យមើលឯកសារសម្ងាត់បំផុត**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីការពារក្តីលោក ខៀវ សំផន**

លោក ស សូវាន

លោក Jacques VERGES

លោក Philippe GRECIANO

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mariette SABATIER

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Mme Silvia CARTWRIGHT

ចៅក្រម យូ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា**៖

លោកស្រី ជា លាង

លោក Andrew CAYLEY

កញ្ញា Mathilde CHIFFERT
កញ្ញា អ៊ុំច ស្រីផាត

ក្រុមមេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់

ក្រុមមេធាវីខាងការពារក្តីទាំងអស់

## សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តីរបស់លោក អៀង សារី បានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតឲ្យខ្លួនមានលទ្ធភាពពិនិត្យមើលគ្រប់ឯកសារសម្ងាត់បំផុតទាំងអស់នៅក្នុងសំណុំរឿង ឬជាជម្រើសម្យ៉ាងទៀត ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ពិនិត្យ *ជាអសាធារណៈ* លើគ្រប់ឯកសារសម្ងាត់បំផុតទាំងអស់នេះ ដើម្បីកំណត់ថា តើឯកសារណាខ្លះ ប្រសិនបើមាន គួរលាតត្រដាងដល់ក្រុមការពារក្តី ដោយមិនគិត ថាតើឯកសារទាំងនោះ អាចនឹងត្រូវបង្ហាញនៅក្នុងពេលជំនុំជម្រះ ឬក៏មិនបង្ហាញនោះឡើយ។[1]

២. ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តីរបស់លោកស្រី អៀង ធីរិទ្ធ បានគាំទ្រសំណើមួយផ្នែករបស់លោក អៀង សារី ដោយសុំរក្សាជំហរដែលថា សំណុំឯកសារ និងរបាយការណ៍វេជ្ជសាស្ត្រ ត្រូវតែនៅជាឯកសារសម្ងាត់បំផុតដដែល។[2]

៣. តាមរយៈនេះ លោក ខៀវ សំផន ស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតឲ្យលោកអាចពិនិត្យមើលគ្រប់ឯកសារសម្ងាត់បំផុតទាំងអស់ ដែលសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី មានបំណងយកទៅប្រើប្រាស់ក្នុងពេលជំនុំជម្រះ សុំឲ្យធានាថា លោកមានលទ្ធភាពទទួលបាននូវគ្រប់ឯកសារដោះបន្ទុកទាំងអស់ និងសុំឲ្យរក្សាការរឹតត្បិតក្នុងការពិនិត្យមើលឯកសារវេជ្ជសាស្ត្រ។

## I.ឯកសារដែលមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី

៤. ដូចការកត់សម្គាល់របស់លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ ដូច្នោះដែរ សហព្រះរាជអាជ្ញា[3] និងដើមបណ្តឹងរដ្ឋប្បវេណី[4] បានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារដែលខ្លួនមានបំណងបង្ហាញនៅក្នុងពេលជំនុំជម្រះ នូវឯកសារដែលចាត់ចូលជាឯកសារសម្ងាត់

---

[1] សំណើរបស់លោក អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E118 (“សំណើរបស់លោក អៀង សារី”)។ ឯកសារនេះជាភាសាបារាំងត្រូវបានផ្តល់មកនៅ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១។

[2] ញត្តិរបស់ លោកស្រី អៀង ធីរិទ្ធ គាំទ្រសំណើមួយផ្នែករបស់លោក អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុត ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E118/1 (“សំណើរបស់លោកស្រី អៀង ធីរិទ្ធ”)។

[3] សំណើរបស់លោក អៀង សារី កថាខណ្ឌទី២ កំណត់ហេតុជើងទំព័រ ពីលេខ ៣ ដល់លេខ ៥

[4] សំណើរបស់លោកស្រី អៀង ធីរិទ្ធ កថាខណ្ឌទី៤ កំណត់ហេតុជើងទំព័រ ពីលេខ ៤ ដល់លេខ ៦

បំផុត ក្នុងចំណោមឯកសារចំនួនជាង ៥០០០ ដែលខាងការពារក្តីមិនមានលទ្ធភាពអាចពិនិត្យមើលបាន និងដឹងត្រឹមតែចំណងជើងទូទៅប៉ុណ្ណោះ។

៥. ការរឹតត្បិតក្នុងការពិនិត្យមើលឯកសារនេះ រំលោភលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌[5] ដែលចេញមកពីគោលការណ៍បដិវាទកម្មនៃនីតិវិធីព្រហ្មទណ្ឌ សមភាពនៃមធ្យោបាយតទល់ក្តី[6] និងព្រមទាំងសិទ្ធិទទួលបាននូវការបង្កលក្ខណៈងាយស្រួលចាំបាច់សម្រាប់រៀបចំការការពារក្តីរបស់ជនជាប់ចោទ។[7] នៅក្នុងរឿងក្តី *Öcalan* អង្គជំនុំជម្រះជាន់ខ្ពស់នៃតុលាការសិទ្ធិមនុស្សអឺរ៉ុប (CEDH) បានប្រកាសថា ៖

> "គោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តី គឺជាធាតុមួយនៃសញ្ញាណដ៏ទូលំទូលាយជាងនោះ នៃការកាត់ក្តីប្រកបដោយយុត្តិធម៌ ដែលមានរួមបញ្ចូលទាំងសិទ្ធិមូលដ្ឋានជាមួយនឹងលក្ខណៈបដិវាទកម្មនៃនីតិវិធីព្រហ្មទណ្ឌ។ សិទ្ធិទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ដែលមានលក្ខណៈបដិវាទកម្ម សម្រាប់ខាងអយ្យការក៏ដូចជាខាងការពារក្តី គឺទាមទារឱ្យមានសមត្ថភាពក្នុងការយល់ដឹងច្បាស់ពីសេចក្តីសង្កេត ឬភស្តុតាងដែលផ្តល់ដោយភាគីម្ខាងទៀត ព្រមទាំងពិភាក្សាលើចំណុចទាំងអស់នោះផង។ ច្បាប់ជាតិអាចបំពេញតម្រូវការចំពោះការទាមទារនេះតាមរបៀបផ្សេងៗ ប៉ុន្តែវិធីសាស្ត្រដែលអនុម័តដោយច្បាប់ជាតិនេះ ត្រូវតែធានាយ៉ាងណាឱ្យខាងការពារក្តី ទទួលបាននូវលទ្ធភាពដ៏ពិតប្រាកដក្នុងការវិភាគលើបទចោទប្រកាន់ទាំងឡាយ"។ [8]

៦. គោលការណ៍មូលដ្ឋាននេះធ្វើឱ្យយើងយល់យ៉ាងច្បាស់ថា ជនជាប់ចោទ**ត្រូវតែពិនិត្យបាន**នូវគ្រប់ឯកសារ**ទាំងអស់** ដែលសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី មានបំណងយកមកបង្ហាញនៅក្នុងពេលជំនុំជម្រះ។ ដើម្បីរៀបចំការការពារក្តីរបស់ខ្លួន លោក ខៀវ សំផន ត្រូវតែអាចយល់ដឹងពីខ្លឹមសារនៃឯកសារទាំងនេះ និងមានលទ្ធភាពជំទាស់លើការទទួលយកឯកសារទាំងនោះ។

---

[5] មាត្រា១២.២ នៃកិច្ចព្រមព្រៀង របស់ អ.វ.ត.ក ។ មាត្រា៣៣ (ថ្មី) នៃច្បាប់បង្កើត អ.វ.ត.ក ។ វិធាន ២១.១ នៃវិធានផ្ទៃក្នុង។

[6] រឿងក្តី កាំង ហ្គេចអ៊ាវ សំណុំរឿងលេខ 001/18-07-2007-ECCC/TC, *Decision on IENG Sary's Request to Make Submission in Response to the Co-Prosecutors' Request for the Application of Joint Criminal Enterprise*, ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារលេខ D288/6.90 កថាខណ្ឌទី៤។

[7] មាត្រា១៣.១ នៃកិច្ចព្រមព្រៀង របស់ អ.វ.ត.ក ។ មាត្រា៣៥ (ថ្មី) នៃច្បាប់បង្កើត អ.វ.ត.ក ។

[8] រឿងក្តី *Öcalan c. Turquie*, សំណើសុំលេខ 46221/99 សាលដីកាអង្គជំនុំជម្រះជាន់ខ្ពស់ នៃតុលាការសិទ្ធិមនុស្សអឺរ៉ុប ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌទី១៤៦ (នៅក្នុងច្បាប់ដើម មិនមានគូសបន្ទាត់ពីក្រោមទេ។

## II. ភស្តុតាងដោះបន្ទុកជាយថាហេតុ

៧. ក្នុងចំណោមឯកសារទាំង ៥០០០ច្បាប់ ដែលចាត់ចូលជាឯកសារសម្ងាត់បំផុត ហើយដែលមិនមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី នោះប្រហែលជាអាចមានឯកសារខ្លះដែលល្អសមស្របសម្រាប់ក្រុមមេធាវីការពារក្តី ហើយដែលក្រុមមេធាវីការពារក្តីត្រូវអាចទទួលបានផងដែរ។

៨. ពីព្រោះថា សញ្ញាណនៃការកាត់សេចក្តីមួយប្រកបដោយយុត្តិធម៌ ក៏រួមបញ្ចូលផងដែរនូវសិទ្ធិក្នុងការពិនិត្យភស្តុតាងដោះបន្ទុក។[9] ទាំងគោលការណ៍ ដែលហៅថា "សមភាពនៃមធ្យោបាយតទល់ក្តី" ក៏ដូចជា "ការបង្កលក្ខណៈងាយស្រួល" ដែលជនជាប់ចោទម្នាក់ៗត្រូវទទួលបាន សុទ្ធតែរួមបញ្ចូលនូវលទ្ធភាពក្នុងការដឹង ពីលទ្ធផលនៃការស៊ើបសួរ សម្រាប់ការពារក្តីរបស់ពួកគាត់ ដែលអាចប្រើប្រាស់សម្រាប់ដោះបន្ទុក ឬទទួលបានការបន្ធូរបន្ថយទោស ។[10]

៩. សាលាឧទ្ធរណ៍នៃតុលាការពិសេស តែងតែរំឭកឥតឈប់ឈរថា ការផ្សព្វផ្សាយពីភស្តុតាងដោះបន្ទុក ដល់ខាងការពារក្តី គឺជា "ចំណុចសំខាន់បំផុត" និង "ចាំបាច់ សម្រាប់ការកាត់ក្តីប្រកបដោយយុត្តិធម៌ ចំពោះមុខតុលាការ"។[11] សាលាឧទ្ធរណ៍នេះក៏បានបញ្ជាក់ដែរថា ការទាមទារខាងលើនេះ តម្រូវឱ្យមានជាដាច់ខាត ដោយមិនគិតពី **លក្ខណៈសាធារណៈ ឬលក្ខណៈសម្ងាត់**នៃភស្តុតាងដែលពាក់ព័ន្ធឡើយ។[12]

---

[9] ភស្តុតាងដែល « ដោះបន្ទុកជនជាប់ចោទ ឬដែលមានទំនោរទៅរកការដោះបន្ទុក ឬសម្រាលទោសជនជាប់ចោទ ឬក៏មានលក្ខណៈកាត់បន្ថយជំនឿលើភស្តុតាងដាក់បន្ទុក » មាត្រា៦៧.២ នៃលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ សូមអានផងដែរនូវមាត្រា ៦៨ នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការ ពិសេស (*ad hoc*)។

[10] រឿងក្តី *Jespers តទល់នឹងប្រទេស Belgique*, លេខ 8493 របាយការណ៍នៃគណៈកម្មការអឺរ៉ុបដើម្បីសិទ្ធិមនុស្ស (១៩៨១) កថាខណ្ឌទី ៥៨។ សូមអានផងដែរ រឿងក្តី *Edwards និង Lewis តទល់នឹងចក្រភពអង់គ្លេស* **សំណើសុំលេខ 39647/98 និង 40461/98** សាលដីកាបស់អង្គជំនុំជម្រះជាន់ខ្ពស់នៃ CEDH ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ កថាខណ្ឌទី៤៦។ រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង Dušco Tadić* រឿងក្តីលេខ IT-94-I-A សាលដីកាចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌទី ៥២។

[11] ជាឧទាហរណ៍ សូមអានរឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង Radislav Krstić* រឿងក្តីលេខ IT-98-33A សាលដីកាចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌទី១៨០។

[12] រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង Tihomir Blaškić* រឿងក្តីលេខ IT-95-14-A សាលដីកាចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌទី២៦៧។

១០. ក្នុងន័យនេះ សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (CPI) ដែលផ្អែកទៅលើយុត្តិសាស្ត្រ នៃតុលាការសិទ្ធិមនុស្សអឺរ៉ុប (CEDH) បានរំឭកពីតួនាទីដែលផ្តល់ជូនដល់ចៅក្រម ក្នុងការ "ធានាឱ្យបាននូវដំណើរប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌ និងប្រកបដោយការខិតខំប្រឹងប្រែង នៃការកាត់ក្តី និងការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ"។ សាលាឧទ្ធរណ៍នេះបានទាញបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូង ជាអ្នក**ត្រួតពិនិត្យជាប្រចាំ**លើការកម្រិតក្នុងការផ្តល់ភស្តុតាង និងធ្វើយ៉ាងណាឱ្យឯកសារសម្ងាត់ដែលមានលក្ខណៈដោះបន្ទុកត្រូវបានផ្តល់ដល់ខាងការពារក្តី។ [13]

១១. ក្នុងករណីពិសេសនេះ ដោយអនុលោមទៅតាមច្បាប់អនុវត្តន៍ចំពោះមុខ អ.វ.ត.ក[14] អង្គជំនុំជម្រះសាលាដំបូង**ត្រូវធ្វើយ៉ាងណា**ធានាឱ្យបាននូវ ការកាត់ក្តីប្រកបដោយយុត្តិធម៌។ ដូច្នេះលោក ខៀវ សំផន ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង មេត្តាធ្វើការពិនិត្យរាល់ឯកសារសម្ងាត់បំផុតទាំងអស់ ដើម្បីកំណត់ភស្តុតាងដោះបន្ទុកជាយថាហេតុ និងផ្តល់ភស្តុតាងទាំងនោះជូនដល់ក្រុមមេធាវីការពារក្តី។

## III. ឯកសារវេជ្ជសាស្ត្រ

១២. ដូចគ្នានឹងក្រុមមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ[15] ដែរ លោក ខៀវ សំផន លើកឡើងថា ក្នុងចំណោមឯកសារដែលសម្ងាត់បំផុត ដែលក្រុមមេធាវីលោក អៀង សារី មានបំណងចូលពិនិត្យមើលនោះ មានឯកសារវេជ្ជសាស្ត្រពាក់ព័ន្ធនឹងរូបលោកផងដែរ។[16]

---

[13] រឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង* *Thomas Lubanga Dyilo* រឿងក្តីលេខ ICC-01/04-01/06 OA 13 សាលដីកាទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ រដ្ឋអាជ្ញាប្រឆាំងទៅនឹងសេចក្តីសម្រេច ពាក់ព័ន្ធនឹងផលវិបាក ដែលបណ្តាលមកពីការមិនផ្តល់ព័ត៌មានស្តីពីភស្តុតាងដោះបន្ទុក ដែលចែងដោយកិច្ចព្រមព្រៀង នៅក្នុងមាត្រា៥៤.៣.ង នៃលក្ខន្តិកៈ ដើម្បីឆ្លើយទៅតាមសំណើសុំព្យួរការចោទប្រកាន់ដែលធ្វើឡើងប្រឆាំងនឹងជនជាប់ចោទ និងដើម្បីឆ្លើយទៅនឹងសំណួរមួយចំនួនទៀតដែលចោទឡើង ក្នុងកិច្ចប្រជុំត្រៀមរៀបចំសវនាការថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ ធ្វើឡើងដោយសាលាដំបូង I ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌទី ៤៦ និង ៤៧។

[14] មាត្រា៣៣ (ថ្មី) នៃច្បាប់បង្កើត អ.វ.ត.ក ៖ « អង្គជំនុំជម្រះសាលាដំបូង**ត្រូវ**ប្រព្រឹត្តទៅឱ្យបាន**ត្រឹមត្រូវ** »។

[15] សំណើរបស់លោកស្រី អៀង ធីរិទ្ធ កថាខណ្ឌទី៧ ។

[16] ជាឧទាហរណ៍ សូមអានឯកសារ B23 និង E13 (00741743-00741748 និង 00741866) ដែលមាននៅក្នុងបញ្ជីក្នុងឧបសម្ព័ន្ធនៃសំណើសុំរបស់ លោក អៀង សារី ឯកសារលេខ E118.1.1។

១៣. ចំណាត់ថ្នាក់ឯកសារទាំងនេះថាជាឯកសារ "សម្ងាត់បំផុត" ដែលមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តន៍របស់ អ.វ.ត.ក[17] នោះ មានមូលដ្ឋានបង្អែក នៅក្នុងសិទ្ធិទទួលបានការគោរពដល់ជីវិតឯកជន។[18] គោលការណ៍នៃការមិនផ្សព្វផ្សាយពីព័ត៌មានវេជ្ជសាស្ត្រដោយគ្មានការព្រមព្រៀងពីអ្នកជំងឺ ក៏អាចយកមកថ្លឹងថ្លែងជាមួយនឹងអត្ថប្រយោជន៍ដទៃទៀត ដូចការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូង ថ្មីៗនេះ ពាក់ព័ន្ធនឹងរបាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញ លើបញ្ហាសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមដំណើរការសវនាការ មុននឹងបដិសេធឱ្យចូលពិនិត្យមើលឯកសារទាំងនេះ។[19]

១៤. ក្នុងករណីពិសេសនេះ វាពុំមែនជារបាយការណ៍របស់អ្នកជំនាញ ដែលធ្វើឡើងតាមដីកាតុលាការនោះឡើយ តែគ្រាន់តែជាព័ត៌មានធម្មតា ដែលទទួលបានក្នុងក្របខណ្ឌនៃទំនាក់ទំនងរវាងអ្នកជំងឺ និងគ្រូពេទ្យ ដោយគ្មានទំនាក់ទំនងសូម្បីតែបន្តិចទៅនឹការត្រៀមការពារក្តីរបស់ភាគីណាមួយឡើយ ដូច្នេះ មិនមានជាប់ពាក់ព័ន្ធអ្វីឡើយ ហើយក៏មិនមានភាពចាំបាច់មានការពិភាក្សាតទល់អ្វីឡើយ។ ការរៀបចំធ្វើចំណាត់ថ្នាក់ឯកសារវេជ្ជសាស្ត្រទាំងនេះឡើងវិញ គឺជា**ការជ្រៀតជ្រែក**ចូលក្នុងជីវិតឯកជនរបស់លោក ខៀវ សំផន **ដោយគ្មានសម្អាងត្រឹមត្រូវ** ហើយបំពានលើ "សិទ្ធិ [...] ទទួលបានការរក្សាការសម្ងាត់ ចំពោះព័ត៌មានវេជ្ជសាស្ត្រទាក់ទិននឹងរូបលោក"។[20]

## អាស្រ័យហេតុនេះ

១៥. សូមអង្គជំនុំជម្រះសាលាដំបូង មេត្តា**អនុញ្ញាត** ឱ្យ ៖

- ក្រុមមេធាវីការពារក្តី ចូលពិនិត្យមើលឯកសារសម្ងាត់បំផុត ដែលមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី

[17] មាត្រា ៦.១.គ នៃសេចក្តីណែនាំអនុវត្តន៍ ទាក់ទិននឹងចំណាត់ថ្នាក់ និងការរក្សាភស្តុតាងដែលដាក់បញ្ចូលក្នុងសំណុំរឿង ពាក់ព័ន្ធនឹង « រាល់ព័ត៌មានទាក់ទិននឹងស្ថានភាពសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ »។

[18] មាត្រា ១៧.១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។

[19] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើ "សារណាស្តីពីការស្នើសុំពិចារណាឡើងវិញ និងកែតម្រូវអនុស្សរណៈ E62/3/10/4 " (ឯកសារ E62/3/10/4/1 និងសំណើសុំ E117) បង្ហាញជូនដោយសហមេធាវីនាំមុខ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E117/2 កថាខណ្ឌទី២

[20] *ដូចខាងលើ*

- **ពិនិត្យ** រាល់ឯកសារសម្ងាត់បំផុត និងឲ្យក្រុមមេធាវីការពារក្តី អាចពិនិត្យមើលឯកសារភស្តុតាងដោះបន្ទុកដែលអាចមានជាយថាហេតុ
- **បដិសេធ** សំណើសុំពិនិត្យមើលឯកសារវេជ្ជសាស្ត្រ ទាក់ទងនឹងលោក ខៀវ សំផន ។

**រក្សាសិទ្ធិគ្រប់យ៉ាង**
**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| p. | មេធាវី ស សុវាន<br><br>មេធាវី Jacques VERGÈS | ភ្នំពេញ<br><br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |